ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ:......៦៧១.......សកបយ.

ភ្នំពេញ,ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០០០

# ប្រកាស

## ស្តីពី

## ការដាក់លក្ខខណ្ឌការងារសំរាប់វិជ្ជាជីវៈ ដែលមិនទាន់មានអនុសញ្ញារួម

---※---

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/ ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦៩៩ / ០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## <u>សំរេច</u>

<u>ប្រការ ១</u>: នៅពេលមិនទាន់មានអនុសញ្ញារួមនៅក្នុងផ្នែកវិជ្ជាជីវៈណាមួយ ឬនៅក្នុងក្របខ័ណ្ឌភូមិសាស្ត្រណាមួយ ការដាក់អោយអនុវត្តលក្ខខណ្ឌការងារមួយចំនួនសំរាប់វិជ្ជាជីវៈ ឬសំរាប់ក្របខ័ណ្ឌភូមិសាស្ត្រនោះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

<u>ប្រការ ២</u> : ការកំណត់លក្ខខណ្ឌការងារសំរាប់ផ្នែកវិជ្ជាជីវៈ ឬក្របខ័ណ្ឌភូមិសាស្ត្រខាងលើត្រូវផ្អែកលើបទប្បញ្ញត្តិនៃអនុសញ្ញារួមដែលអនុវត្តនៅក្នុងផ្នែកវិជ្ជាជីវៈ ឬក្របខ័ណ្ឌភូមិសាស្ត្រប្រហាក់ប្រហែលគ្នា ដែលមានលក្ខខណ្ឌសេដ្ឋកិច្ចស្រដៀងគ្នា ។

<u>ប្រការ ៣</u> : ក្នុងអំឡុងពេល ១៥ ថ្ងៃយ៉ាងតិច បន្ទាប់ពីថ្ងៃផ្ញើសេចក្តីព្រាងប្រកាសជូនសមាជិកគណៈកម្មការប្រឹក្សាការងារមក ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងធ្វើការកោះប្រជុំគណៈកម្មការប្រឹក្សាការងារ ដើម្បីពិនិត្យពិភាក្សាលើការសំរេចដាក់អោយអនុវត្ត លក្ខខណ្ឌការងារសំរាប់វិជ្ជាជីវៈណាមួយ ឬក្របខ័ណ្ឌភូមិសាស្ត្រណាមួយនោះ ។

<u>ប្រការ ៤</u> : ក្រោយពេលពិគ្រោះពិភាក្សា ដោយឯកភាពយោបល់ជាមួយគណៈកម្មការប្រឹក្សាការងារ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចេញប្រកាសផ្សព្វផ្សាយអោយអនុវត្តលក្ខខណ្ឌការងារសំរាប់ផ្នែកវិជ្ជាជីវៈ ឬក្របខ័ណ្ឌភូមិសាស្ត្រនោះ ។
លក្ខខណ្ឌការងារ ដែលបានកំណត់ខាងលើ ត្រូវមានប្រសិទ្ធិភាពអនុវត្តតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

<u>ប្រការ ៥</u> : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃ ចុះហត្ថលេខានេះ តទៅ ។

<u>ចម្លងជូន:</u>

- ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត- ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក "ដើម្បីអនុវត្ត"
- សហភាពសហជីព "ដើម្បីអនុវត្ត"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និង ឯកសារ

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**